# របាយការណ៍ប្រចាំខែសីហា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែសីហា ឆ្នាំ ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **<u>ស្ថានភាពមន្ត្រីរាជការ</u>**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣០ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **<u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>**÷

- ចូលរួមកិច្ចប្រជុំសាមញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីថ្ងៃទី ២២/០៧/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ផ្លូវថ្នល់ ថ្ងៃទី ២២/០៧/២០១៥ នៅសាលប្រជុំសាលមហោស្រពខេត្ត
- ចូលរួមប្រជុំសាមញ្ញលើកទី ១៤ អាណត្តិទី ២ ឆ្នាំទី២របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី ២៣/០៧ ២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមកម្មវិធីវិនិយោគឃុំបុសលាវ ថ្ងៃទី ៣០/០៧/២០១៥ នៅសាលាឃុំបុសលាវ
- ចូលរួមប្រជុំវិសាមញ្ញលើកទី ១១ អាណត្តិទី ២ ឆ្នាំទី ២ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី ៣០/០៧/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីជួរមុខគណៈកម្មាធិការជួញដូរមនុស្សនៅថ្ងៃទី ០៦-០៧/០៨/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សាអំពីឡូតិ៍ដីជូនមុខសញ្ញាទទួលដីឃុំដារ និងឃុំចំបក់ថ្ងៃទី១០/០៨/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យប្រចាំខែកក្កដា ឆ្នាំ២០១៥ ថ្ងៃទី ១១/០៨/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមវាយតម្លៃប្រគល់ទទួលការផ្គត់ផ្គង់សម្ភារៈនិងបរិក្ខាបច្ចេកទេសថ្ងៃទី ១៣/០៨/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រកាសតែងតាំងប្រធានមន្ទីរធម្មការ និងសាសនា ថ្ងៃទី១៧/០៨/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ថ្ងៃទី១៨/០៨/២០១៥ នៅសាលប្រជុំសាលាខេត្ត

- ចូលរួមពិនិត្យ វាស់វែង និងសិក្សាផលប៉ះពាល់ដីរបស់ប្រជាពលរដ្ឋនៅក្នុងក្រុមហ៊ុនស្ថិតនៅឃុំឃ្សឹម ស្រុកស្នួល ថ្ងៃទី១៩-២៩/០៨/២០១៥។

3. **សកម្មភាពតាមការិយាល័យ÷**

3.1. **ការិយាល័យរដ្ឋបាល និងបុគ្គលិក÷**

ក. ផ្នែកការងារលិខិតចូល÷ សរុបចំនួន ៥៣ លេខ ក្នុងនោះមាន:

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០៤ លេខ
- លិខិតរបស់ក្រសួងសាមី ចំនួន ០៦ លេខ
- លិខិតក្រសួងនានា ចំនួន ០២ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៤០ លេខ

ខ. ផ្នែកការងារលិខិតចេញ÷ សរុបចំនួន ២៦ លេខ ក្នុងនោះមាន:

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ០៧ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ១៩ លេខ

គ-លិខិតឧទ្ទេសនាម÷ សរុបចំនួន ០១លេខ

ឃ. ផ្នែកការងារលិខិតបញ្ជាបេសកកម្ម÷ សរុបចំនួន ១៣ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកកម្មលោកប្រធានមន្ទីរ ពី **ឯកឧត្តមអភិបាលខេត្ត** ចំនួន ០១ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ១២ លេខ

ង. ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **ការិយាល័យផ្លូវជនបទ÷**

**សកម្មភាពការងារ**

- ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ក្នុងបានចំនួន ០៥ ខ្សែ ប្រវែង ៥៩ ៨០០ ម៉ែត្រ ស្ថិតនៅឃុំស្វាយជ្រះ ឃុំឃ្សឹម ឃុំស្នួល ឃុំ២ធ្នូ ស្រុកស្នួល
- ចុះពិនិត្យស្ថានភាពទឹកជំនន់តាមព្រែកឆ្លង ដែលបាននាំសម្រាស់ឬស្សី មកជាប់ហ្នឹងសសរគ្រឹះស្ពាន កំពង់ស្រែ ឃុំឆ្លូង ស្រុកឆ្លូង
- ចុះពិនិត្យការងារជួសជុលបន្ទាន់ផ្លូវ បុកទឹក-ព្រែកប្រាំង ២ ៧០០ ម៉ែត្រ ឃុំព្រែកប្រសព្វ ស្រុក ព្រែកប្រសព្វ
- ចុះពិនិត្យការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប ផ្លូវសិរ៉ាង-ចឹង ប្រវែង ៨ ០០០ ម៉ែត្រ ស្ថិត នៅឃុំឃ្សឹម ស្រុកស្នួល និងផ្លូវក្បាលស្នួល-ស្នួលកើត ប្រវែង ៤ ០០០ ម៉ែត្រ ស្ថិតនៅឃុំស្នួល ស្រុកស្នួល
- បញ្ជាក់បច្ចេកទេសលើព័ត៌មានគម្រោងមូលនិធិឃុំ សង្កាត់ របស់ទីចាត់ការផែនការនិង វិនិយោគសាលាខេត្តក្រចេះបានចំនួន ១០ ច្បាប់។

**លទ្ធផលការងារ**

- ការងារផ្លូសជុលបន្ទាន់ផ្លូវ បុកទឹក-ព្រៃកប្រាំង ២ ៧០០ ម៉ែត្រ ឃុំព្រៃកប្រសព្វ ស្រុកព្រៃកប្រសព្វ លទ្ធផលសម្រេចបាន ១០០%
- ការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប ផ្លូវសំរ៉ង-ចឹង ប្រវែង ៨ ០០០ ម៉ែត្រ ស្ថិតនៅឃុំឃ្សឹម ស្រុកស្នួល និងផ្លូវក្បាលស្នួល-ស្នួលកើត ប្រវែង ៤ ០០០ ម៉ែត្រ ស្ថិតនៅឃុំស្នួល ស្រុកស្នួល លទ្ធផលសម្រេចបាន ៦០%
- មន្ទីរសហការជាមួយអាជ្ញាធរស្រុកឆ្លូងចំនួន ០៣ លើក ដើម្បីទាញសម្រាប់ឬស្សីមកជាប់ហ្នឹង សសរ គ្រឹះស្ពាន ដោយចំណាយថវិការអស់ ១៥០០០០០ រៀល ក្នុងនោះមន្ទីរជួយចេញ ៧៥០០០០ រៀល ។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ**÷

- ជួសជុលអណ្តូងស្នប់បានចំនួន ៩០ អណ្តូង÷
- ស្រុកស្នួល ៥៩ អណ្តូង ស្ថិតនៅឃុំខ្ញូ ២៥ អណ្តូង,ឃុំស្រែចារ ៣៤ អណ្តូង
- ស្រុកចិត្របុរី ១៨ អណ្តូង ស្ថិតនៅឃុំកន្ទួត ០៥ អណ្តូង,ឃុំដារ ០១ អណ្តូង, ឃុំគោលាប់ (០៥+ ដូរស្នប់AFថ្មី០១=០៦អណ្តូង ), ឃុំចង្ក្រង់ (០៤+ ដូរស្នប់AFថ្មី ០២=០៦អណ្តូង )
- ស្រុកឆ្លូង០៣ អណ្តូង ស្ថិតនៅ ឃុំជីវិតថ្មុង ០៣ អណ្តូង
- ក្រុងក្រចេះ០៤ អណ្តូង ស្ថិតនៅសង្កាត់ក្រគរ ០៤ អណ្តូង
- ស្រុកសំបូរ ០៦ អណ្តូង ស្ថិតនៅឃុំសំបូរ ០៥ អណ្តូង,ឃុំកោះខ្ញែរ ០១ អណ្តូង។

3.4. **ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**÷ (គ្មានសកម្មភាព)

3.5. **ការិយាល័យអភិវឌ្ឍន៍សហគមន៍**÷

- ចុះរៀបចំ គ.អ.ភ នៅភូមិសម្បទានកំពី ឃុំសំបុក ស្រុកចិត្របុរី មានអ្នកចូលរួម ១១ នាក់ ស្រ្តី ០៥ នាក់។
- ចុះសហការជាមួយឆាលហ្វាន់ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលសម្ព័ន្ធ គ.អ.ភ និងពង្រឹង គ.អ.ភ ពីភាពទទួលខុសត្រូវរបស់ គ.អ.ភ បានចំនួន ២០ ភូមិ ០៤ ឃុំ (ឃុំកំពង់ជីវី ឃុំជីវិតថ្មុង ឃុំព្រៃកសាម៉ាន់ ឃុំកញ្ជរ) ក្នុងស្រុកឆ្លូង មានអ្នកចូលរួមចំនួន ១៦០ នាក់ ស្រ្តី ៦៥ នាក់។

3.6. **ការិយាល័យជនជាតិដើមភាគតិច÷** (គ្មានសកម្មភាព)

3.7. **ការិយាល័យថែទាំសុខភាពជនបទ**÷ (គ្មានសកម្មភាព)

3.8. **ការងារបណ្តុះបណ្តាលមន្ត្រីរាជការ**÷

- ចុះផ្សព្វផ្សាយ សកម្មភាពស្តីពីការលើកកម្ពស់អនាម័យតាមសហគមន៍ និងពង្រឹងបណ្តាញជន បង្គោលស្ម័គ្រចិត្តភូមិជ្រើសរើសអ្នកស្ម័គ្រចិត្តសាងសង់បង្គន់អនាម័យតាមគ្រួសារ

- ស្រុកព្រៃកប្រសព្វ ឃុំព្រោយបន្ទាយមាន ០៤ ភូមិមានអ្នកចូលរួមប្រជុំ ១១៣ នាក់ ស្ត្រី ៨៥ នាក់ កុមារ ២១ នាក់
- ស្រុកសំបូរ ឃុំវ៉ឌ្ឍនះ០៤ ភូមិមានអ្នកចូលរួមប្រជុំ ១២២ នាក់ ស្ត្រី ៨០ នាក់ កុមារ ១៩ នាក់

– បំផុសអោយប្រជាពលរដ្ឋចូលរួមស្ម័គ្រចិត្តសាងសង់បង្គន់ខ្លួនឯង នៅឃុំចង្ក្រង់ ស្រុកចិត្របុរី មានគ្រួសារក្រ១ និងក្រ២ ចំនួន ១១គ្រួសារ និងគ្រួសារគ្មានបណ្ណ ចំនួន ៣១ គ្រួសារ៕